NSW Police Force

# **សេចក្តីថ្លែងការណ៍ទាក់ទងនឹងការដាក់ពង្រាយបុគ្គលិកកងកម្លាំងការពារអូស្ត្រាលី (ADF)**

ថ្ងៃសៅរ៍ ទី 31 ខែកក្កដា ឆ្នាំ 2021 ម៉ោង 03:29:53 ល្ងាច

សេចក្តីថ្លែងការណ៍ពីស្នងការប៉ូលិសរដ្ឋ NSW លោក Mick Fuller ទាក់ទងនឹងការដាក់ពង្រាយបុគ្គលិកកងកម្លាំងការពារអូស្ត្រាលី (ADF)។

កម្លាំងប៉ូលិសរដ្ឋ NSW កំពុងពង្រីកយ៉ាងខ្លាំងនូវសកម្មភាពអនុលោមតាមច្បាប់ និងសុខុមាលភាព COVID-19 របស់ខ្លួននៅក្នុងស៊ីនីយ៍ (Sydney) ក្នុងពេលប៉ុន្មានថ្ងៃខាងមុខ ហើយខ្ញុំបានស្នើសុំបុគ្គលិកកងកម្លាំងការពារអូស្ត្រាលី (ADF) ចំនួន 300 នាក់ដើម្បីពង្រឹងតំបន់ប្រតិបត្តិការរបស់យើង។

នេះមានន័យថាមន្ត្រីប៉ូលិសនានានឹងត្រូវបានជួយដោយបុគ្គលិកកង កម្លាំងការពារអូស្ត្រាលី (ADF) នៅពេលពួកគេផ្តល់ការដឹកជញ្ជូនកញ្ចប់ម្ហូបអាហារ ដឹកនាំការគោះទ្វារសុខុមាលភាព និងធ្វើការពិនិត្យមើលលើការអនុលោមតាមច្បាប់ចំពោះបទបញ្ជាឱ្យស្នាក់នៅផ្ទះ និងបទបញ្ជាដាក់ឱ្យនៅដោយឡែកពីគេ។

ប្រតិបត្តិការនេះនឹងត្រូវបានដឹកនាំ និងគ្រប់គ្រងដោយកម្លាំងប៉ូលិសរដ្ឋ NSW។

ADF នឹងមានវត្តមានក្នុងតួនាទីជួយគាំទ្រ នៅក្រោមការណែនាំរបស់កម្លាំងប៉ូលិសរដ្ឋ NSW។

ប្រតិបត្តិការនេះនឹងផ្តោតជាសំខាន់ទាក់ទងនឹងសុខុមាលភាពសហគមន៍ និងធានាថាបទបញ្ជាឱ្យស្នាក់នៅផ្ទះ ដែលចេញដោយខុទ្ទកាល័យ... 

ADF បានផ្តល់ជំនួយសំខាន់ក្នុងរយៈពេលជាង 18 ខែកន្លងទៅ – ជាពិសេសក្នុងអំឡុងប្រតិបត្តិការព្រំដែននៅឆ្នាំកន្លងទៅ ប្រតិបត្តិការចត្តាឡីស័កនៅតាមសណ្ឋាគារជាបន្តបន្ទាប់ និងជំនួយដែលបានផ្តល់ជាមួយនឹងជំនួយ គាំទ្រភស្តុភារនៅមជ្ឈមណ្ឌលប្រតិបត្តិការប៉ូលិស។

ADF ពីមុនមកក៏បានផ្តល់ជំនួយក្នុងការឆ្លើយតបទៅនឹងភ្លើងឆេះព្រៃ និងទឹកជំនន់ផងដែរ។

កម្លាំងប៉ូលិសរដ្ឋ NSW នឹងបន្តធ្វើការជាមួយសហគមន៍ដើម្បីធានាសុខុមាលភាព និងសុវត្ថិភាពមនុស្សគ្រប់រូប នៅក្នុងរដ្ឋ NSW។

NSW GOVERNMENT

COVID19 CORONAVIRUS DISEASE